ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃអង្គារ ទី២៤ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៩:០០នាទីនៅក្នុងរោងចក្រហ៊ុងស៊ីង ហ្គាមិន (ខេមបូឌា)ឯ.ក អាស័យដ្ឋាន ផ្លូវជាតិលេខ២ ភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទីខេត្តតាកែវ ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-អ្នកស្រី Zhang Shirley (ប្រធានរោងចក្រ)

-លោក តាំង ឡុង (ប្រធានផ្នែករដ្ឋបាល)

-កញ្ញា អ៊ឹម វិសា (គណនេយ្យ)

### ខ. ភាគីតំណាងសមាជិក និងតំណាងកម្មករនិយោជិត ប្រធានក្រុម

១-លោក ឈិត ម៉េងគ្រុយ ២-លោក ឌិន ឌាន់ ៣-អ្នកស្រី នៅ សុលី ៤-លោក ភន ភ័ក្ត

៥-លោក នួន រ៉ា ៦-លោក វ៉ែន សំបូរ ៧-លោក អាំ សុភក្រ្តិ ៩-ឃួន វណ្ណា ១០-ធា ផានិន ១១-សម្បត្តិ ស៊ុនហេង ១២-បូ បុប្ផា ១៣- លោកស្រី ម៉ុត កេសី។

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០២ ខែដោយចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ ដោយមូលហេតុពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោម៖

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន២៥ដុល្លា សម្រាប់១ខែពេលព្យួរការងារ ៥០ដុល្លា សម្រាប់២ខែនៃការព្យួរកិច្ចសន្យាការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្តើមព្យួរការងារ កម្មករនិយោជិត ចំនួន ៩៩នាក់ ស្រី ៨៤នាក់។ ចាប់ផ្តើមពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ ។

២. រោងចក្រផ្តល់ប្រាក់ឈ្នួលគោល២៥ដុល្លា សម្រាប់១ខែក្នុងពេលព្យួរការងារ ៥០ដុល្លា សម្រាប់២ខែនៃការព្យួរកិច្ចសន្យាការងារ។

៣.ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

៤.ចំពោះប្រាក់ឈ្នួលរោងចក្រ និងបើកជូនមិនលើសពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១០:១០ នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

## ក.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត



Scanned with CamScanner

ខ.<u>តាគីប្រធានក្រុម</u>

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

ហ៊ុងស៊ីង ហ្គាម៉ិន
រដ្ឋបាល
人事專用章
HUNG HSING GARMENT

ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ហ៊ុងស៊ីង ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

Scanned with CamScanner